ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
លេខាធិការដ្ឋាន គ.ជ.អ.ប

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និង ព័ត៌មាន

រាជធានីភ្នំពេញ, ថ្ងៃទី...០៣...ខែ...កញ្ញា...ឆ្នាំ២០១៥

លេខ:...២០៤.................../អតវ

## សូមគោរពជូន

## ឯកឧត្តមអនុប្រធានប្រតិបត្តិនៃលេខាធិការដ្ឋាន គ.ជ.អ.ប

**កម្មវត្ថុ:** របាយការណ៍សង្ខេបកិច្ចប្រជុំជាមួយតំណាងអង្គការសង្គមស៊ីវិលស្តីពីការត្រៀមរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម(PSC)។

**យោង:** -លិខិតចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម។

-ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ នៅបន្ទប់ប្រជុំរបស់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអភិបាលកិច្ច(GRLC) មានរៀបចំកិច្ចប្រជុំក្រៅផ្លូវការមួយជាមួយតំណាងអង្គការសង្គមស៊ីវិល រួមមាន៖ CCC, PACT Cambodia, Save the Children, World Vision។ កិច្ចប្រជុំនេះប្រព្រឹត្តិទៅក្រោមអធិបតីភាព ឯកឧត្តម ងី ច័ន្ទ្រផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក្នុងគោលបំណង ដើម្បីពិភាក្សាអំពីការត្រៀមរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម កិច្ចប្រជុំលើកទី១ និងបញ្ហាពាក់ព័ន្ធមួយចំនួន។

សូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបផងដែរថា សមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម មានចំនួន១៤រូប ដឹកនាំដោយប្រធាន១រូប (ឯកឧត្តម ងី ច័ន្ទ្រផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ) និងអនុប្រធាន ១រូប (តំណាងអង្គការសង្គមស៊ីវិល) ព្រមទាំងសមាជិកចំនួន១០រូប ដែលមកពីផ្នែកផ្គត់ផ្គង់ចំនួន ៥រូប និងផ្នែកតម្រូវការចំនួន ៥រូប និងអ្នកអង្កេតការណ៍ចំនួន ២រូប មកពីដៃគូអភិវឌ្ឍន៍។

អង្គប្រជុំបានពិភាក្សា និងកំណត់ចំនុចឯកភាពមួយចំនួនដូចខាងក្រោម៖

១-សមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម នឹងត្រូវរៀបចំបង្កើតស្របតាមស្មារតីខ្លឹមសាលិខិតចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ របស់លេខាធិករដ្ឋាន គ.ជ.អ.ប។

២-តំណាងអង្គការសង្គមស៊ីវិលបានជ្រើសរើសលោក សឿង សារឿន ដែលបច្ចុប្បន្នជានាយកប្រតិបត្តិនៃអង្គការ (គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ជាអនុប្រធាន នៃ PSC និងសមាជិកចំនួន ៥រូប មកពីអង្គការ Save the Children, Pact Cambodia, Racha, World Vision និងអង្គការ WGPD។ តំណាងអង្គការសង្គមស៊ីវិលត្រូវផ្ញើរឈ្មោះសមាជិកទាំង៥រូប នោះមកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីរៀបចំសេចក្តីសម្រេចតែងតាំង។

៣-ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវរៀបចំសំណើរទៅក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាត់មន្ត្រីជាន់ខ្ពស់ចូលជាសមាជិករបស់PSC។

៤-ឯកឧត្តមអធិបតីអង្គប្រជុំ បានឯកភាពកែសម្រួលល័ក្ខខ័ណ្ឌការងារ (TOR) របស់ PSC ដោយបន្ថែមក្នុងចំនុចទី៥ **"ក្នុងករណីប្រធាន PSC អវត្តមាន អនុប្រធានត្រូវទទួលសិទ្ធិជាប្រធានស្តីទីដោយមានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធាន"**។

៥-អង្គប្រជុំពុំទាន់បានព្រមព្រៀងគ្នាលើចំនុចការរៀបចំលេខាធិការដ្ឋានរបស់PSCនៅឡើយទេ ដោយប្រើប្រាស់ក្រុមការងារមានបច្ចុប្បន្ន និងបន្តពិភាក្សាគ្នាពេលក្រោយទៀត។

៦-បន្ទាប់ពីចេញសេចក្តីសម្រេចបង្កើតPSC រួចទើបមានការប្រជុំលើកទី១របស់PSC ដែលគ្រោងធ្វើនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ ខាងមុខ។

៧-អង្គប្រជុំបានគ្រោងរបៀបវារៈសម្រាប់កិច្ចប្រជុំលើកទី១របស់PSC ដូចខាងក្រោមៈ

- -ពិនិត្យផែនការអនុវត្តបីឆ្នាំ និងផែនការថវិកាសម្រាប់អនុវត្ត I-SAF
- -ពិនិត្យផ្តល់យោបល់លើអនុស្សារណៈយោគយល់គ្នា (MOU) រវាងលេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការសង្គមស៊ីវិលក្នុងការ អនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម។
- -កំណត់ស្រុកគោលដៅអនុវត្ត I-SAF សម្រាប់ឆ្នាំ២០១៦ ២០១៧ និងឆ្នាំ២០១៨
- -ពិនិត្យចុងក្រោយ និងសម្រេចលើលក្ខខ័ណ្ឌការងាររបស់ PSC
- -រៀបចំប្រតិទិន នៃកិច្ចប្រជុំបន្ទាប់។

ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប នឹងពិភាក្សាជាមួយអង្គការសងស៊ីវិលពីរបៀបវារៈនេះបន្តទៀត។

បន្ទាប់ពីកិច្ចប្រជុំ អង្គការសង្គមស៊ីវិលបានបញ្ជូនឈ្មោះតំណាងរបស់ខ្លួនចំនួន៥រូប ចូលជាសមាជិកនៃ PSC មកឯកឧត្តមប្រធានគណៈកម្មាធិការនេះ រួចរាល់ហើយ (ដូចមានក្នុងឯកសារជូនភ្ជាប់មកជាមួយ)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាបជារបាយការណ៍និងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ជ.ប្រធានអង្គភាព

ជេដ្ឋ គីមជុង

03/09/15

ទិវាន់ ចំរើន

សក់_សេដ្ឋា

08.09.15

លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

National Committee for Sub National Democratic Development Secretariat

# បញ្ជីវត្តមាន

List of Participant

ស្ដីពី (Subject) : Pre-Meeting befor 1st PSC meeting

កន្លែងប្រជុំ (Place) : DFGG Meeting Room

កាលបរិច្ឆេទ (Date) : 27/08/2015, 9:00am

| ល.រ Nº | នាម និងគោត្តនាម Name | ភេទ Sex | ក្រសួង-ស្ថាប័ន-ក្រុមហ៊ុន Ministry/Company | តួនាទី Position | លេខទូរស័ព្ទ Telephone | អ៊ីមែល Email | ហត្ថលេខា Signature |
|---|---|---|---|---|---|---|---|
| 1 | Ngy Chanphal | M | MOI | SoS/MOI | 012909879 ~~012412076~~ | MRDNGYCP@online.com.kh | |
| 2 | Chath Kim chung | M | | Deputy. HEID/NCDDS | 012758520 | Kimchung@ncdd.gov.kh | |
| 3 | Mot Sana | M | Save the children | Director of Program | 017584727 | sana.mot@savethechildren.org | |
| 4 | Soeung Saroeun | M | CCC | Executive Director | 016900503 | saroeun.soeung@ccc-cambodia.org | |
| 5 | Steven Cooke | M | World Vision | Advocacy Manager | 012760797 | steve_cooke@wvi.org | |
| 6 | Sophal Chhor | M | Pact | Governance & Decentralization Director | (012)868099 | schhor@pactworld.org | |
| 7 | TUY Pheap | M | NCDDS | M&E Advisor | 012288005 | pheap@ncdd.gov.kh | |
| 8 | Bouth Chik | M | MOI | GRLC | 011359807 | chik.dj66@gmail.com | |
| 9 | Sar Monthea | F | NCDDS | SSA | 012442145 | monthea.sar@ncdd.gov.kh | |
| 10 | But Sokchamroeun | M | NCDDS | SAO | 012761455 | sokchamroeun.but@ncdd.gov.kh | |
| 11 | Chhay Raksmey | M | MOI | Assistant H.E.Ngy Chanphal | 012412076 | raksmey.chhay@yahoo.com | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |